00721417

E62/3/10/4

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

# អង្គជំនុំជម្រះសាលាដំបូង

កាលបរិច្ឆេទ: ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១១

**ជូនចំពោះ:** **សហមេធាវីនាំមុខតំណាងដើមបណ្តឹង រដ្ឋប្បវេណី និងភាគីទាំងអស់នៃសំណុំរឿង ០០២**

**ពី:** **ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង**

**ចម្លងជូន:** **លោក/លោកស្រីចៅក្រមទាំងអស់នៃអង្គជំនុំជម្រះសាលាដំបូង និងមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង**

**កម្មវត្ថុ:** **សេចក្តីសម្រេចលើ "សារណាបន្ទាន់ស្នើសុំអង្គជំនុំជម្រះសាលាដំបូងឲ្យកែតម្រូវអនុស្សរណៈ E62/3/10" (លេខឯកសារ E62/3/10/1)**

យោងតាមសំណើខាងលើដែលស្នើសុំឱ្យអង្គជំនុំជម្រះកែតម្រូវអនុស្សរណៈមុនរបស់ខ្លួន ដែលបានចេញកាលពីថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០១១ (លេខឯកសារ E62/3/10/1) ដើម្បីអនុញ្ញាតឱ្យមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់អាចពិនិត្យមើល ដោយគ្មានការរិតត្បិតនូវរបាយការណ៍វេជ្ជសាស្ត្ររបស់សាស្ត្រាចារ្យ John Campbell នៃអង្គជំនុំជម្រះសាលាដំបូង ("សំណើ")។ អំណះអំណាងខាងក្រោមគឺជាមូលដ្ឋាននៃសំណើខាងលើ៖

- ការអនុញ្ញាតឱ្យតែសហមេធាវីនាំមុខមានសិទ្ធិពិនិត្យរបាយការណ៍វេជ្ជសាស្ត្រ គឺជាការរឹតត្បិតមួយដែលរំលោភទៅលើគោលការណ៍ជាសារវ័ន្ត ដែលបានអនុញ្ញាតឱ្យមេធាវីទាំងអស់ដែលកំពុងចូលរួមក្នុងកិច្ចដំណើរការនីតិវិធីអាចពិនិត្យមើលឯកសារបាន និងជាការរំលោភគោលការណ៍សមភាពនៃមធ្យោបាយតទល់ក្តី និងភារកិច្ចរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្នុងការតំណាងកូនក្តីរបស់ខ្លួន ដោយអនុលោមតាមវិធាន ២៣ ស្ទួន(២) (សំណើ, កថាខណ្ឌ ១០-១៣, ១៩-២៤)

- ដោយហេតុថាសហមេធាវីនាំមុខពុំអាចទទួលបានការឯកភាព និងការសម្របសម្រួលក្នុងការតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដែលតម្រូវដោយវិធាន១២ស្ទួន២(៣) (សំណើកថាខណ្ឌ១៤-១៧)។

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 29 / 07 / 2011
ម៉ោង (Time/Heure): 14:30
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé: Ratanak

អនុស្សរណៈមុនរបស់អង្គជំនុំជម្រះដែលមានលេខឯកសារ E62/3/10 បានទទួលស្គាល់រួចហើយថា៖

- ការជំទាស់របស់ក្រុមមេធាវីការពារក្ដីចំនួន២ ទៅនឹងការដាក់របាយការណ៍វេជ្ជសាស្ត្រទាំងនេះទៅក្នុងផ្នែកសម្ងាត់នៃសំណុំរឿង ដោយសារភាពចាំបាច់ដែលតម្រូវឲ្យសហព្រះរាជអាជ្ញាអាចពិនិត្យមើលរបាយការណ៍នេះដោយគ្មានការរឹតត្បិត ដើម្បីសហព្រះរាជអាជ្ញាសម្រេចថាតើខ្លួនត្រូវជំទាស់ ឬគាំទ្រការវាយតម្លៃនៅក្នុងរបាយការណ៍ទាំងនោះ និងភាពចាំបាច់ដែលត្រូវធានាថាកិច្ចដំណើរការនីតិវិធីប្រព្រឹត្តទៅដោយឆាប់រហ័ស
- សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ទទួលបានសំណៅថតចម្លងនៃរបាយការណ៍កោសល្យវិច័យនេះទាំងស្រុង។ ពួកគេអាចប្រគល់របាយការណ៍នេះទៅឲ្យមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីម្នាក់ៗ នៅពេលណាមានការឯកភាពដោយអនុលោមតាមវិធាន១២ស្ទួន២(៥)(ខ) និង (៦) នៃវិធានផ្ទៃក្នុង ដែលបានចែងថាមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីត្រូវធ្វើសារណាដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរតំណាងឲ្យផលប្រយោជន៍នៃបណ្ដុំនៃដើមបណ្ដឹងរដ្ឋប្បវេណីដែលរួមគ្នាជាក្រុមតែមួយ។
- ភាពចាំបាច់ក្នុងការរក្សាតុល្យភាពរវាងសិទ្ធិជនជាប់ចោទក្នុងការរក្សាភាពសម្ងាត់ ពាក់ព័ន្ធនឹងព័ត៌មានវេជ្ជសាស្ត្រផ្ទាល់ខ្លួនទល់នឹងសិទ្ធិរបស់សាធារណៈជនក្នុងការដឹងអំពីព័ត៌មានទាំងនេះនៅពេលដែលការសម្រេចលើពាក្យសុំពាក់ព័ន្ធនឹងសម្បទារបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះ កំពុងស្ថិតនៅក្នុងការពិចារណានៅឡើយ។

អង្គជំនុំជម្រះសម្គាល់ឃើញថាក្នុងក្របខណ្ឌគតិយុត្តនៅ អ.វ.ត.ក ដើមបណ្ដឹងរដ្ឋប្បវេណីចាប់ពីដំណាក់កាលជំនុំជម្រះតទៅបង្កើតបានជាបណ្ដុំនៃដើមបណ្ដឹងរដ្ឋប្បវេណីដែលរួមគ្នាជាក្រុមតែមួយ ដែលមានសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ជាអ្នកតំណាងផលប្រយោជន៍របស់ពួកគេ (វិធាន២៣(៣))។ សហមេធាវីនាំមុខជាអ្នកទទួលខុសត្រូវចុងក្រោយទៅកាន់តុលាការសម្រាប់ការផ្ដល់ការអះអាង និងយុទ្ធសាស្ត្រជាទូទៅ ព្រមទាំងការតំណាងចំពោះមុខតុលាការនូវផលប្រយោជន៍របស់បណ្ដុំដើមបណ្ដឹងរដ្ឋប្បវេណីដែលបានរួមគ្នាជាក្រុមតែមួយនោះចាប់ពីដំណាក់កាលជំនុំជម្រះតទៅ (វិធាន១២ស្ទួន២(៥))។ មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីមានតួនាទីជួយដល់សហមេធាវីនាំមុខ ក្នុងការអនុវត្តការទទួលខុសត្រូវទាំងនេះ ដែលកូនក្ដីខ្លួនតំណាងលែងបន្តចូលរួមកិច្ចនីតិវិធីនៅសវនាការជាលក្ខណៈបុគ្គល (វិធាន ២៣(៣))។ យន្តការពិគ្រោះយោបល់ដូចមានចែងក្នុងវិធាន១២ស្ទួន២(៣) ត្រូវបានលើកឡើងនៅក្នុងវិធាន ២៣(៣) ក្នុងលក្ខណៈជាបែបបទមួយដើម្បីផ្ដល់ប្រសិទ្ធភាពដល់ការជួយជ្រោមជ្រែងដល់សហមេធាវីនាំមុខ ពីសំណាក់មេធាវីតំណាងដើម-

បណ្តឹងរដ្ឋប្បវេណី។ បន្ទាប់ពីមានពាក្យពេចន៍ច្បាស់លាស់ថា "សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីត្រូវស្វែងរកទស្សនៈផ្សេងៗពីមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ហើយនិងព្យាយាមសម្របសម្រួលឲ្យអស់ពីលទ្ធភាពដើម្បីឈានទៅដល់ការឯកភាពគ្នាជាឯកច្ឆន្ទ...") ទើបបញ្ញត្តិនេះពុំទាមទារឲ្យសហមេធាវីនាំមុខត្រូវមានការឯកភាពពីមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីនៅគ្រប់ដំណាក់កាល ពិសេសស្ថានភាពមួយដែលមិនស្របជាមួយកាតព្វកិច្ចចម្បងរបស់សហមេធាវីនាំមុខក្នុងការ "ធានាឲ្យមានប្រសិទ្ធភាពនូវការរៀបចំការតំណាងដើមបណ្តឹងរដ្ឋប្បវេណីចាប់ពីដំណាក់កាលជំនុំជម្រះតទៅ... ដែលធ្វើឲ្យមានតុល្យភាពនូវសិទ្ធិរបស់ភាគីទាំងអស់ និងតម្រូវការឲ្យការជំនុំជម្រះប្រព្រឹត្តទៅបានឆាប់រហ័សក្នុងបរិបទពិសេសរបស់ អ.វ.ត.ក" (វិធាន ១២ស្ទួន២(១))។

អាស្រ័យហេតុនេះ អង្គជំនុំជម្រះយល់ថាអនុស្សរណៈលេខ E62/3/10/1 ពុំបានរំលោភទៅលើសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី ឬមេធាវីរបស់ពួកគេឡើយ ហើយក៏ពុំបានរំលោភសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការទទួលបានការតំណាងគ្រប់គ្រាន់នៅក្នុងបរិបទនេះ ឬបង្ហាញនូវអតុល្យភាពណាមួយដែរ។ ដោយពិចារណាទៅលើគោលបំណងនៃសកម្មភាពរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខ អ.វ.ត.ក ក្នុង "ការចូលរួមកិច្ចនីតិវិធីព្រហ្មទណ្ឌប្រឆាំងនឹងអ្នកទទួលខុសត្រូវលើបទល្មើសក្រោមយុត្តាធិការ អ.វ.ត.ក តាមរយៈការជួយគាំទ្រការចោទប្រកាន់"នោះ ពុំមានការរំលោភណាមួយទៅលើគោលការណ៍សមភាពមធ្យោបាយតទល់ក្តីឡើយ។ សំណើនេះបានទទួលស្គាល់ (កថាខណ្ឌ ១៨) សារៈសំខាន់ចម្បងនៃការគោរពភាពសម្ងាត់ ដែលជាមូលដ្ឋាននៃសេចក្តីបង្គាប់មុនរបស់អង្គជំនុំជម្រះសាលាដំបូង ដើម្បីធានាបាននូវភាពសម្ងាត់នៃព័ត៌មានវេជ្ជសាស្ត្រ។

អនុស្សរណៈមុនរបស់អង្គជំនុំជម្រះបានអនុញ្ញាតឲ្យសហមេធាវីនាំមុខចែកចាយរបាយការណ៍ទាំងនេះ នៅពេលចាំបាច់ដើម្បីជួយសហមេធាវីនាំមុខក្នុងការរៀបចំសារណាជាលាយលក្ខណ៍អក្សរ ឬផ្ទាល់មាត់ស្តីពីបញ្ហានេះ ប្រសិនបើពួកគាត់ប្រគល់ភារកិច្ចមួយផ្នែក ឬទាំងអស់មកឲ្យមេធាវីដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ៗ។ អង្គជំនុំជម្រះបដិសេធសំណើសុំឲ្យកែតម្រូវសេចក្តីណែនាំមុនរបស់ខ្លួន ដើម្បីអនុញ្ញាតឲ្យមេធាវីដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ រួមទាំងបុគ្គលដែលនឹងពុំមានតួនាទីសកម្មពាក់ព័ន្ធនឹងបញ្ហានេះអាចពិនិត្យមើលរបាយការណ៍វេជ្ជសាស្ត្រ។

នេះគឺជាចម្លើយតបជាផ្លូវការពីមតិភាគច្រើននៃចៅក្រមអង្គជំនុំជម្រះទៅនឹងសំណើលេខ E62/3/10/1។ លោកចៅក្រម Lavergne មានមតិជំទាស់។ មូលហេតុនៃការជំទាស់របស់លោកចៅក្រមនឹងចេញនៅពេលសមស្របខាងមុខ។